

# វត្ថុខ្មៅវេទមន្ត

Let's Read
The Asia Foundation



រីកា ស្រលាញ់អក្សរសរសេររបស់បងប្រុសនាងខ្លាំងណាស់។
បងប្រុសរបស់ រីកា សរសេរអក្សរជាមួយប៊ិកភ្លឺរលោងមួយដើម។



នាថ្ងៃមួយ ពេលបងប្រុសរបស់ រីកា មិននៅផ្ទះ រីកា បានទៅរក
ប៊ិករបស់បងប្រុស។ រីកា បានបើកថតតុរបស់បងប្រុស។



រីកា គ្រវែងសៀវភៅ ប្រដាប់កឹបក្រដាស និងបន្ទាត់ដែករបស់បងប្រុសចេញពីថតតុអស់រលីង!



ទីបំផុត រីកា ក៏រកឃើញប៊ិកពិសេសរបស់បងប្រុស។
អូ! នេះជាអ្វី?
មានវត្ថុខ្មៅមួយជុំជាប់នឹងប៊ិក។



រីកា ទាញវត្ថុខ្មៅនោះចេញពីប៊ិក។ រំពេចនោះស្រាប់តែ...
ប្លឹក...! ខឹប...!
គម្របប៊ិកហោះទៅជាប់នឹងវត្ថុខ្មៅនោះ។
តើនេះជាវេទមន្តមែនទេ? រីកា សួរខ្លួនឯង។



រីកា ឆ្ងល់ខ្លាំងណាស់ថាតើវត្ថុខ្មៅនេះជាអ្វី។ រីកា យកវត្ថុខ្មៅដាក់ជិតប្រដាប់កឹបក្រដាស...

ប្លឹក...! ខឹប...! វាទាញជាប់គ្នា!

រីកា យកវត្ថុខ្មៅដាក់ជិតឆ្មា តែវាអត់ទាញជាប់គ្នាទេ។



វីកា ដាក់វត្ថុខ្មៅជិតបន្ទាត់ដែក។ ភ្លាមនោះ...
ប្លីក...! ខឹប...! វាទាញជាប់គ្នា!



រីកា ដាក់វត្ថុខ្មៅជិតផ្លែដូង តែវាអត់ទាញជាប់គ្នាទេ!



អាឈើស...!

រីកា កណ្តាស់យ៉ាងខ្លាំង ព្រោះស្រកីដូងធ្វើអោយច្រមុះរបស់រីការសើប។

ហើយបិកជ្រុះពីដៃ រីកា និងចូលក្រោមគ្រែបាត់។ រីកា ភ័យខ្លាំងពីព្រោះបងប្រុសរបស់នាងជិតត្រលប់មកវិញ។



រីកា ព្យាយាមលូកដៃទៅក្រោមគ្រែយកប៊ិក តែលូកអត់ដល់សោះ។



រីកា យកបន្ទាត់មកទាញប៊ិក តែប៊ិកកាន់តែទៅឆ្ងាយ។ រីកា សួរខ្លួនឯងថាតើមានវិធីណា ដើម្បីអោយប៊ិកខិតជិតដែរឬទេ?



ភ្លាមនោះ នាងនឹកឃើញវិធីមួយ!



រីកា យកបន្ទាត់ដែកទៅដាក់ជាប់វត្ថុខ្មៅ។
ប្លឹក...!ខឹប...!
បន្ទាប់មក រីកា យកបន្ទាត់ធ្វើជាដងកាន់ ហើយរុញវាអោយខិតជិតនឹងប៊ិក។



ប្លឹក...! ខឹប...! បិកជាប់ហើយ!!!



រីកា ប្រញាប់ប្រញាល់ប្រមូលប៊ិក វត្ថុខ្មៅ សៀវភៅ ប្រដាប់កឹបក្រដាស និងបន្ទាត់ដែកដាក់ចូលក្នុងថតតុវិញ។



ទាន់ពេលល្មម! បងប្រុសរបស់ វីកា ដើរចូលមកក្នុងបន្ទប់ និង សួរថា "វីកា! ហេតុអ្វីមានផ្លែដូងក្នុងបន្ទប់បង?"



អាថ៌កំបាំងនៃវត្ថុខ្មៅ!

តាមពិតទៅ វត្ថុខ្មៅនោះ គឺជាមេដែកដែលអាចឆក់ទាញលោហធាតុបាន តែមិនអាចទាញវត្ថុដែលមិនមែនជាលោហៈបានទេ។ មេដែកមានច្រើនទម្រង់ អាចមានរាងមូល ចតុកោណកាវ៉េ ឬ អក្សរយូ។

លោហធាតុមានដូចជា ដែក ជាតិនីកែល ដែកថែប និងគូប៉ល។



តើវត្ថុណាខ្លះដែលមេដែកអាចឆក់បាន?

Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*The Magic Block*, Published by Pratham Books, © Pratham Books. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/
Contributing translators: Solyda Say and Nhean Socheat